ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៥៤៣១ ប្រក

# ប្រកាស
# ស្តីពី
# ការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញា
# រដ្ឋបាលក្រុងស្ទឹងសែន ខេត្តកំពង់ធំ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- យោងតាមសំណើរបស់រដ្ឋបាលខេត្តកំពង់ធំ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតនិមិត្តសញ្ញារដ្ឋបាលក្រុងស្ទឹងសែន ខេត្តកំពង់ធំ មានរូបរាង រូបភាព និងលក្ខណៈសម្គាល់ដូចខាងក្រោម៖

- និមិត្តសញ្ញាមានរាងមូល បង្ហាញអំពីការគ្រប់គ្រងដែនដីរបស់រដ្ឋបាលក្រុង
- ដំរីសម្បុរខ្មៅមួយក្បាលជាន់ខ្លាមួយក្បាល និងខ្លាមួយក្បាលទៀតឡើងខាំខ្នងដំរី ឈរនៅទម្រថ្មពណ៌បៃតងនិងត្នោតកសាងឆ្នាំ១៩៦០ ជាតំណាងនៃសត្វដំរីនិងខ្លាជាប្រភេទសត្វព្រៃប្រយុទ្ធគ្នាយកឈ្នះចាញ់ ហើយក៏បង្ហាញអំពីការធ្វើសង្គ្រាមរវាងក្រុងរាពណ៍ជាមួយនឹងហនុមាន និងអង្គទក្នុងរឿងរាមកេរ្តិ៍
- ស្ពានថ្មពណ៌លឿងមួយខ្សែ ដែលកសាងសម័យអាណានិគមបារាំងឆ្នាំ១៩២០ បង្ហាញអំពីស្ពានដ៏ចំណាស់ឆ្លងកាត់ស្ទឹងសែន ដែលជាប្រវត្តិសាស្ត្ររវាងកម្ពុជានិងបារាំង ហើយស្ពានថ្មកំពង់ធំនេះត្រូវបានអភិរក្សនៅពេលបច្ចុប្បន្នផងដែរ
- ស្ទឹងសែនពោរពេញដោយទឹកប្រៀបបានទឹករដូវវស្សា បង្ហាញអំពីស្ទឹងធម្មជាតិដែលហូរពីជួរភ្នំដងរែកហូតដល់បឹងទន្លេសាបសម្រាប់បម្រើតម្រូវការរបស់មនុស្ស សត្វ ជម្រកមច្ឆា និងវិស័យកសិកម្ម
- អក្សរឈ្មោះ «**រដ្ឋបាលក្រុងស្ទឹងសែន**» មានពណ៌ស រំលេចក្នុងខ្សែបូពណ៌ក្រហម អមដោយខ្សែបូពណ៌ខៀវ
- ពពកនិងផ្ទៃពណ៌ផ្ទៃមេឃ បង្ហាញអំពីសន្តិភាព ភាពជឿជាក់ ភាពស្មោះត្រង់ និងភាពអំណត់។

**ប្រការ២ .-**

ត្រូវបានដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលក្រុងស្ទឹងសែន ខេត្តកំពង់ធំ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

និមិត្តសញ្ញារដ្ឋបាលក្រុងស្ទឹងសែន ខេត្តកំពង់ធំ ត្រូវប្រើប្រាស់ដូចខាងក្រោម៖

- ដាក់នៅកន្លែងធ្វើការងារនៅរដ្ឋបាលក្រុងស្ទឹងសែន
- ប្រើប្រាស់នៅលើលិខិត ស្រោមសំបុត្រ និងឯកសារផ្លូវការពាក់ព័ន្ធរបស់រដ្ឋបាលក្រុងស្ទឹងសែន
- ប្រើប្រាស់ក្នុងពិធីនានា និងប្រើប្រាស់ក្នុងកិច្ចការជាផ្លូវការផ្សេងៗ តាមការចាំបាច់។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស ប្រធានអង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ប្រធានក្រុមប្រឹក្សានិងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ប្រធានក្រុមប្រឹក្សានិងអភិបាលនៃគណៈអភិបាលក្រុងស្ទឹងសែន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...សុក្រ...១១កើត...ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- រដ្ឋបាលខេត្តកំពង់ធំ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ៥៤៣១.ប្រក ចុះថ្ងៃ.ព្រហ....១១កើត.ខែ.ភទ្របទ....ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី.១៣...ខែកញ្ញា....ឆ្នាំ២០២៤ ស្តីពីការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលក្រុងស្ទឹងសែន ខេត្តកំពង់ធំ។

**និមិត្តសញ្ញារដ្ឋបាលក្រុងស្ទឹងសែន**

ក្រសួងមហាផ្ទៃ ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ: ៥៤៧៦ ប្រក

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ប្រកាស
## ស្តីពី
## ការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញា រដ្ឋបាលស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនង ការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- យោងតាមសំណើរបស់រដ្ឋបាលខេត្តកំពង់ធំ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតនិមិត្តសញ្ញារដ្ឋបាលស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ មានរូបរាង រូបភាព និងលក្ខណៈសម្គាល់ដូចខាងក្រោម៖

- និមិត្តសញ្ញាមានរាងមូលព័ទ្ធដោយខ្សែវណ្ឌពណ៌ត្នោតស្រដៀងពណ៌ថ្មបាយក្រៀមមួយជាន់បង្ហាញអំពីការគ្រប់គ្រងដែនដីរបស់រដ្ឋបាលស្រុក

- ដាវដែក និងស្រោមដាវមានពណ៌ត្នោតទ្រេដោយទម្រប្អូនជ្រុង និងទម្រប្រាំបីជ្រុងរចនាជាទម្រង់ផ្កាឈូកពណ៌មាស ជាតំណាងនៃសាស្ត្រាមួយប្រភេទធ្វើពីដែក ដែលផលិតដោយជនជាតិភាគតិចកួយរស់នៅស្រុកកំពង់ស្វាយក្នុងសម័យបុរាណ ហើយត្រូវបានហៅថាដាវដែកកំពង់ស្វាយ រហូតដល់សព្វថ្ងៃនេះ។ ដាវដែកកំពង់ស្វាយនេះក៏បង្ហាញអំពីមហិទ្ធិឫទ្ធិដ៏ខ្លាំងក្លា ហើយត្រូវប្រជាជនពោលជាកាព្យថា «ដាវអើញដាវដែក ដាវល្អចម្លែក ដាវដែកកំពង់ស្វាយ ផ្លែបានពីឪពុក ស្រោមបានពីម្ដាយ ដាវដែកកំពង់ស្វាយ កម្ចាយអស់សត្រូវ» ដែលប្រើប្រាស់ក្នុងពិធីមង្គលនានាតាមប្រពៃណីរបស់ខ្មែរផងដែរ
- អក្សរឈ្មោះ «**រដ្ឋបាលស្រុកកំពង់ស្វាយ**» មានពណ៌ស រំលេចក្នុងផ្ទៃពណ៌ក្រហមអមដោយខ្សែប្ញពណ៌ខៀវ
- ផ្ទៃពណ៌ស បង្ហាញអំពីភាពជឿជាក់ ភាពស្មោះត្រង់ និងភាពត្រជាក់ត្រជុំ។

**ប្រការ២ .-**

ត្រូវបានដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

និមិត្តសញ្ញារដ្ឋបាលស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ត្រូវប្រើប្រាស់ដូចខាងក្រោម៖

- ដាក់នៅកន្លែងធ្វើការងារនៅរដ្ឋបាលស្រុកកំពង់ស្វាយ
- ប្រើប្រាស់នៅលើលិខិត ស្រោមសំបុត្រ និងឯកសារផ្លូវការពាក់ព័ន្ធរបស់រដ្ឋបាលស្រុកកំពង់ស្វាយ
- ប្រើប្រាស់ក្នុងពិធីនានា និងប្រើប្រាស់ក្នុងកិច្ចការជាផ្លូវការផ្សេងៗតាមការចាំបាច់។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស ប្រធានអង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ប្រធានក្រុមប្រឹក្សានិងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ប្រធានក្រុមប្រឹក្សានិងអភិបាលនៃគណៈអភិបាលស្រុកកំពង់ស្វាយ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...សុក្រ.....១១កើត....ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...១៣...ខែ...កញ្ញា......ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- រដ្ឋបាលខេត្តកំពង់ធំ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ..៥៤៧៦...ប្រក ចុះថ្ងៃ..សុក្រ...១១កើត..ខែភទ្របទ...ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី..១៣...ខែកញ្ញា....ឆ្នាំ២០២៤ ស្ដីពីការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។

**និមិត្តសញ្ញារដ្ឋបាលស្រុកកំពង់ស្វាយ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ: ៥៤៧៣ ប្រក

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ប្រកាស
## ស្តីពី
## ការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញា
## រដ្ឋបាលស្រុកតាំងគោក ខេត្តកំពង់ធំ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាគណៈអភិបាលខេត្ត ក្រុមប្រឹក្សាគណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- យោងតាមសំណើរបស់រដ្ឋបាលខេត្តកំពង់ធំ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតនិមិត្តសញ្ញារដ្ឋបាលស្រុកតាំងគោក ខេត្តកំពង់ធំ មានរូបរាង រូបភាព និងលក្ខណៈសម្គាល់ដូចខាងក្រោម៖

- និមិត្តសញ្ញាមានរាងមូលព័ទ្ធដោយកម្រងកួរស្រូវពណ៌មាសពាក់កណ្ដាលរង្វង់ បង្ហាញអំពីការគ្រប់គ្រងដែនដីរបស់រដ្ឋបាលស្រុក
- ប្រាសាទគុកនគរមានពណ៌ត្នោត ជាតំណាងនៃប្រាសាទបុរាណសាងសង់ពីថ្មបាយក្រៀមនិងថ្មភក់ នៅលើផ្ទៃរាបស្មើ ក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១ នៅសតវត្សទី១១។ប្រាសាទគុកនគរជាកន្លែងគោរពបូជាក្នុងជំនឿនានា និងរមណីយដ្ឋានប្រវត្តិសាស្ត្រ សម្រាប់បម្រើវិស័យទេសចរណ៍បែបវប្បធម៌ខ្មែរ នាពេលបច្ចុប្បន្ន
- វាលស្មៅបៃតងខ្ចីក្រោយប្រាសាទ បង្ហាញអំពីបរិស្ថានធម្មជាតិដ៏ស្រស់បំព្រងសម្រាប់ជីវិតសត្វ វិស័យកសិកម្ម និងដំណាំផ្សេងៗ
- អក្សរឈ្មោះ «រដ្ឋបាលស្រុកតាំងគោក» មានពណ៌ស រំលេចក្នុងខ្សែបូពណ៌ក្រហមអមដោយខ្សែពណ៌ខៀវ
- ផ្ទៃពណ៌ផ្ទៃមេឃ បង្ហាញអំពីសន្តិភាព ភាពជឿជាក់ ភាពស្មោះត្រង់ និងភាពអំណត់។

**ប្រការ២ .-**

ត្រូវបានដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលស្រុកតាំងគោក ខេត្តកំពង់ធំ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

និមិត្តសញ្ញារដ្ឋបាលស្រុកតាំងគោក ខេត្តកំពង់ធំ ត្រូវប្រើប្រាស់ដូចខាងក្រោម៖

- ដាក់នៅកន្លែងធ្វើការងារនៅរដ្ឋបាលស្រុកតាំងគោក
- ប្រើប្រាស់នៅលើលិខិត ស្រោមសំបុត្រ និងឯកសារផ្លូវការពាក់ព័ន្ធរបស់រដ្ឋបាលស្រុកតាំងគោក
- ប្រើប្រាស់ក្នុងពិធីនានា និងប្រើប្រាស់ក្នុងកិច្ចការជាផ្លូវការផ្សេងៗតាមការចាំបាច់។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស ប្រធានអង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ប្រធានក្រុមប្រឹក្សានិងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ប្រធានក្រុមប្រឹក្សានិងអភិបាលនៃគណៈអភិបាលស្រុកតាំងគោក ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...............ខែ............ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.......ខែ............ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- រដ្ឋបាលខេត្តកំពង់ធំ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ៥៤៣៣.ប្រក ចុះថ្ងៃ.សុក្រ....១១កើត..ខែ..ភទ្របទ......ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៣.ខែកញ្ញា..ឆ្នាំ២០២៤ ស្ដីពីការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលស្រុកតាំងគោក ខេត្តកំពង់ធំ។

## និមិត្តសញ្ញារដ្ឋបាលស្រុកតាំងគោក១/៥

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៥៤៧៣.ប្រក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាស
## ស្តីពី
## ការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញា
## រដ្ឋបាលស្រុកបារាយណ៍ ខេត្តកំពង់ធំ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាគណៈអភិបាលខេត្ត ក្រុមប្រឹក្សាគណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- យោងតាមសំណើរបស់រដ្ឋបាលខេត្តកំពង់ធំ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតនិមិត្តសញ្ញារដ្ឋបាលស្រុកបារាយណ៍ ខេត្តកំពង់ធំ មានរូបរាង រូបភាព និងលក្ខណៈសម្គាល់ដូចខាងក្រោម៖

- និមិត្តសញ្ញាមានរាងមូលព័ទ្ធដោយខ្សែវណ្ឌមួយជាន់ពណ៌មាស បង្ហាញអំពីការគ្រប់គ្រងដែនដីរបស់រដ្ឋបាលស្រុក
- ព្រះខ័នមានផ្ទៃពណ៌ប្រផេះ និងដងពណ៌ត្នោត តម្កល់លើទម្រដែលរចនាក្បាច់និងទ្រង់ទ្រាយបែបបុរាណពណ៌មាស ជាតំណាងនៃសាស្ត្រាមួយប្រភេទដែលព្រះមហាក្សត្របានប្រទានឱ្យស្តេចត្រាញ់នៅតាមដែនដីក្នុងសម័យបុរាណ។ ព្រះខ័ននេះជាព្រះខ័នមួយក្នុងចំណោមព្រះខ័នបីទៀត ដែលរកឃើញនិងតម្កល់ទុកនៅស្រុកបារាយណ៍រហូតដល់សព្វថ្ងៃនេះ។ ម្យ៉ាងទៀត ព្រះខ័ននេះ ក៏បង្ហាញអំពីសិទ្ធិនិងអំណាចក្នុងការគ្រប់គ្រង និងការធ្វើសង្គ្រាមរបស់ស្តេចត្រាញ់ ហើយក៏ជាវត្ថុស័ក្តិសិទ្ធិនៃជំនឿសម្រាប់ធ្វើពិធីបួងសួងនិងបន់ស្រន់នៅក្នុងពិធីជំនឿសាសនានិងប្រពៃណីផ្សេងៗ
- អក្សរឈ្មោះ «រដ្ឋបាលស្រុកបារាយណ៍» មានពណ៌ស រំលេចក្នុងខ្សែបូពណ៌ក្រហមអមដោយខ្សែបូពណ៌ខៀវ
- ផ្ទៃពណ៌ផ្ទៃមេឃ បង្ហាញអំពីសន្តិភាព ភាពជឿជាក់ ភាពស្មោះត្រង់ និងភាពអំណត់។

**ប្រការ២ .-**

ត្រូវបានដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលស្រុកបារាយណ៍ ខេត្តកំពង់ធំ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

និមិត្តសញ្ញារដ្ឋបាលស្រុកបារាយណ៍ ខេត្តកំពង់ធំត្រូវប្រើប្រាស់ដូចខាងក្រោម៖

- ដាក់នៅកន្លែងធ្វើការងារនៅរដ្ឋបាលស្រុកបារាយណ៍
- ប្រើប្រាស់នៅលើលិខិត ស្រោមសំបុត្រ និងឯកសារផ្លូវការពាក់ព័ន្ធរបស់រដ្ឋបាលស្រុកបារាយណ៍
- ប្រើប្រាស់ក្នុងពិធីនានា និងប្រើប្រាស់ក្នុងកិច្ចការជាផ្លូវការផ្សេងៗ តាមការចាំបាច់។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស ប្រធានអង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ប្រធានក្រុមប្រឹក្សានិងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ប្រធានក្រុមប្រឹក្សានិងអភិបាលនៃគណៈអភិបាលស្រុកបារាយណ៍ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...សុក្រ...១១កើត...ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣...ខែ...កញ្ញា.....ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- រដ្ឋបាលខេត្តកំពង់ធំ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ៥៤៣៣ប្រក ចុះថ្ងៃសុក្រ...១១កើត..ខែភទ្របទ....ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី..១៣..ខែកញ្ញា....ឆ្នាំ២០២៤ ស្តីពីការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលស្រុកបារាយណ៍ ខេត្តកំពង់ធំ។

**និមិត្តសញ្ញារដ្ឋបាលស្រុកបារាយណ៍**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ: ៥៤២៧ ប្រក

# ប្រកាស
# ស្តីពី
# ការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញា
# រដ្ឋបាលស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាគណៈអភិបាលខេត្ត ក្រុមប្រឹក្សាគណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- យោងតាមសំណើរបស់រដ្ឋបាលខេត្តកំពង់ធំ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតនិមិត្តសញ្ញារដ្ឋបាលស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ មានរូបរាង រូបភាព និងលក្ខណៈសម្គាល់ ដូចខាងក្រោម៖

- និមិត្តសញ្ញាមានរាងមូលស្រួចខាងលើ ដែលព័ទ្ធដោយខ្សែវណ្ណពីរជាន់រចនាជាក្បាច់ផ្ចឹតស្លឹកឈើ។ ខ្សែខាងក្រៅពណ៌មាសអមដោយខ្សែពណ៌បៃតង និងខ្សែខាងក្នុងពណ៌បៃតង បង្ហាញអំពីការគ្រប់គ្រងដែនដីរបស់រដ្ឋបាលស្រុក

- ប្រាសាទបល្ល័ង្កមានរាងបួនជ្រុងមានពណ៌ត្នោតប្រហែលនឹងពណ៌ឥដ្ឋ ជាតំណាងនៃប្រាសាទបុរាណខ្មែរដែលបានកសាងពីឥដ្ឋលើគ្រឹះថ្មបាយក្រៀម ក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី១ នៅដើមសតវត្សទី១១។ ប្រាសាទបល្ល័ង្កត្រូវបានអភិរក្សជាសម្បត្តិវប្បធម៌ខ្មែរ និងជាកន្លែងទេសចរណ៍នៅក្នុង និងក្រៅស្រុក នាពេលបច្ចុប្បន្ន
- ចង្ក្រានស្លដែក ឬហៅថាសន្លុងស្លដែកពណ៌មាស ជាតំណាងនៃឧបករណ៍ស្លដែកបែបបុរាណរបស់ជនជាតិកួយសម្រាប់ធ្វើដាវ លំពែង និងឧបករណ៍ផ្សេងៗ។ ចង្ក្រានស្លដែក ដែលអ្នកស្រុកនិយមហៅថាសន្លុងស្លដែក បង្ហាញអំពីចំណេះនិងជំនាញស្លដែក ដែលជាប្រពៃណីនិងវប្បធម៌ នៅសម័យបុរាណហើយបានបន្សល់ទុកស្លាកស្នាមនៅក្នុងភូមិសាស្ត្ររបស់ស្រុកនេះ
- អក្សរឈ្មោះ «រដ្ឋបាលស្រុកប្រាសាទបល្ល័ង្ក» មានពណ៌ស រំលេចក្នុងខ្សែបូពណ៌ក្រហម អមដោយខ្សែបូពណ៌ខៀវ
- ផ្ទៃពណ៌ស បង្ហាញអំពីភាពជឿជាក់ ភាពស្មោះត្រង់ និងភាពត្រជាក់ត្រជុំ។

**ប្រការ២ .-**

ត្រូវបានដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

និមិត្តសញ្ញារដ្ឋបាលស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ ត្រូវប្រើប្រាស់ដូចខាងក្រោម៖

- ដាក់នៅកន្លែងធ្វើការងារនៅរដ្ឋបាលស្រុកប្រាសាទបល្ល័ង្ក
- ប្រើប្រាស់នៅលើលិខិត ស្រោមសំបុត្រ និងឯកសារផ្លូវការពាក់ព័ន្ធរបស់រដ្ឋបាលស្រុកប្រាសាទបល្ល័ង្ក
- ប្រើប្រាស់ក្នុងពិធីនានា និងប្រើប្រាស់ក្នុងកិច្ចការជាផ្លូវការផ្សេងៗ តាមការចាំបាច់។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស ប្រធានអង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ប្រធានក្រុមប្រឹក្សានិងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ប្រធានក្រុមប្រឹក្សានិងអភិបាលនៃគណៈអភិបាលស្រុកប្រាសាទបល្ល័ង្ក ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ.សុក្រ.....១១កើត...ខែមិគសិរ.ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.១៣.ខែធ្នូ.....ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- រដ្ឋបាលខេត្តកំពង់ធំ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ៥៤៣៧ប្រក ចុះថ្ងៃ.សុក្រ....១១កើត.ខែភទ្របទ..ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៣.ខែកញ្ញា...ឆ្នាំ២០២៤ ស្ដីពីការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលស្រុកប្រាសាទបល្ល័ង្កខេត្តកំពង់ធំ។

**និមិត្តសញ្ញារដ្ឋបាលស្រុកប្រាសាទបល្ល័ង្ក១៥**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ: ៥៤៧៨ ប្រក

# ប្រកាស
## ស្ដីពី
## ការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញា
## រដ្ឋបាលស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាគណៈអភិបាលខេត្ត ក្រុមប្រឹក្សាគណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- យោងតាមសំណើរបស់រដ្ឋបាលខេត្តកំពង់ធំ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតនិមិត្តសញ្ញារដ្ឋបាលស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ មានរូបរាង រូបភាព និងលក្ខណៈសម្គាល់ដូចខាងក្រោម៖

- និមិត្តសញ្ញាមានរាងមូលព័ទ្ធដោយខ្សែវណ្ឌពីរជាន់ ខាងក្រៅពណ៌ខៀវនិងខាងក្នុងពណ៌លឿងបង្ហាញអំពីការគ្រប់គ្រងដែនដីរបស់រដ្ឋបាលស្រុក
- ប្រាសាទតោធ្វើពីឥដ្ឋមានពណ៌ក្រហមស្រដៀងពណ៌ឥដ្ឋ ជាតំណាងនៃប្រាសាទបុរាណខ្មែរមួយប្រភេទស្ថិតនៅក្នុងតំបន់សំបូរព្រៃគុកដែលកសាងនៅចុងសតវត្សទី៨នៃគ.ស. ដោយព្រះបាទជ័យវរ្ម័នទី២។ ប្រាសាទតោនេះជាទីកន្លែងសម្រាប់បម្រើវិស័យទេសចរណ៍ក្នុងស្រុកនិងក្រៅស្រុក
- តោមួយគូពណ៌ប្រផេះស្រដៀងពណ៌ថ្មភក់ ឈរអមជណ្តើរចូលប្រាសាទ ជាតំណាងនៃសត្វដែលមានកម្លាំងខ្លាំងក្លា ឫទ្ធិនិងអំណាចលើសត្វដទៃ
- វាលស្មៅបៃតងចាស់ បង្ហាញអំពីបរិស្ថានស្រស់បំព្រងជុំវិញប្រាសាទ
- អក្សរឈ្មោះ «រដ្ឋបាលស្រុកប្រាសាទសំបូរ » មានពណ៌ស រំលេចក្នុងខ្សែរបូពណ៌ក្រហមអមដោយខ្សែបូពណ៌ខៀវ
- ពពកពណ៌សក្នុងផ្ទៃពណ៌ផ្ទៃមេឃ បង្ហាញអំពីសន្តិភាព ភាពជឿជាក់ ភាពស្មោះត្រង់ និងភាពអំណត់។

**ប្រការ២ .-**

ត្រូវបានដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

និមិត្តសញ្ញារដ្ឋបាលស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ត្រូវប្រើប្រាស់ដូចខាងក្រោម៖

- ដាក់នៅកន្លែងធ្វើការងារនៅរដ្ឋបាលស្រុកប្រាសាទសំបូរ
- ប្រើប្រាស់នៅលើលិខិត ស្រោមសំបុត្រ និងឯកសារផ្លូវការពាក់ព័ន្ធរបស់រដ្ឋបាលស្រុកប្រាសាទសំបូរ
- ប្រើប្រាស់ក្នុងពិធីនានា និងប្រើប្រាស់ក្នុងកិច្ចការជាផ្លូវការផ្សេងៗ តាមការចាំបាច់។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស ប្រធានអង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ប្រធានក្រុមប្រឹក្សានិងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ប្រធានក្រុមប្រឹក្សានិងអភិបាលនៃគណៈអភិបាលស្រុកប្រាសាទសំបូរ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...សុក្រ...១១កើត...ខែភទ្របទ.ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...១៣...ខែ...កញ្ញា.......ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- រដ្ឋបាលខេត្តកំពង់ធំ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ៥៤៣៨ប្រក ចុះថ្ងៃ.សុក្រ..១១កើត.ខែ.ភទ្របទ....ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៣ខែកញ្ញា....ឆ្នាំ២០២៤ ស្តីពីការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ។

**និមិត្តសញ្ញារដ្ឋបាលស្រុកប្រាសាទសំបូរ១/៥**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ: ៥៤៣៩ ប្រក

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ប្រកាស
# ស្តីពី
# ការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញា រដ្ឋបាលស្រុកសណ្តាន់ ខេត្តកំពង់ធំ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាគណៈអភិបាលខេត្ត ក្រុមប្រឹក្សាគណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- យោងតាមសំណើរបស់រដ្ឋបាលខេត្តកំពង់ធំ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតនិមិត្តសញ្ញារដ្ឋបាលស្រុកសណ្តាន់ ខេត្តកំពង់ធំ មានរូបរាង រូបភាព និងលក្ខណៈសម្គាល់ដូចខាងក្រោម៖

- និមិត្តសញ្ញាមានរាងជារង្វង់មូលព័ទ្ធដោយខ្សែវណ្ណពណ៌មាស បង្ហាញអំពីការគ្រប់គ្រងដែនដីរបស់រដ្ឋបាលស្រុក

- ដើមសណ្តាន់មួយដើមពណ៌បៃតង ជាតំណាងនៃដើមឈើមួយប្រភេទដែលផ្លែនិងស្លឹកមានរសជាតិជូរសម្រាប់ជាម្ហូបរបស់ខ្មែរ។ ដើមសណ្តាន់ដុះនៅក្នុងស្រុក ភូមិ និងព្រៃ ព្រមទាំងដុះតាមមាត់បឹងស្ទឹង និងព្រែក ហើយអ្នកស្រុក ភូមិតែងនិយមហៅភ្ជាប់នឹងទីតាំងជាបឹងសណ្តាន់ ភូមិសណ្តាន់ នៅក្នុងស្រុកសណ្តាន់ផងដែរ
- ជួរភ្នំដីគ្របដណ្តប់ដោយព្រៃឈើ ជាតំណាងនៃភ្នំពីធម្មជាតិ ដែលមានរ៉ែមាស ថ្ម ត្បូង ជម្រកសត្វព្រៃ និងជាតំបន់ទេសចរណ៍ធម្មជាតិរបស់ប្រជាជនក្នុងនិងក្រៅស្រុក
- ទំនប់ស្ទាក់ទឹកជងកាំបិត បង្ហាញអំពីការទប់និងការស្ទាក់ទឹក ដែលមានប្រភពពីទឹកស្ទឹងសែនសម្រាប់ស្រោចស្រពស្រែចំការ ដំណាំផ្សេងៗ និងជាតម្រូវការរបស់មនុស្សនិងសត្វ
- ផ្ទៃក្រឡាខ្វាត់ខ្វែងនិងវាលស្មៅពណ៌បៃតងខ្ចី បង្ហាញអំពីដំណាំស្រូវ ចំការ និងដំណាំហូបផ្លែនានាសម្រាប់ជីវភាពរស់នៅរបស់ប្រជាជន
- អក្សរឈ្មោះ «រដ្ឋបាលស្រុកសណ្តាន់» មានពណ៌ស រំលេចក្នុងខ្សែបូពណ៌ក្រហមអមដោយខ្សែបូពណ៌ខៀវ
- ផ្ទៃពណ៌ផ្ទៃមេឃ បង្ហាញអំពីសន្តិភាព ភាពជឿជាក់ ភាពស្មោះត្រង់ និងភាពអំណត់។

**ប្រការ២ .-**

ត្រូវបានដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលស្រុកសណ្តាន់ ខេត្តកំពង់ធំ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

និមិត្តសញ្ញារដ្ឋបាលស្រុកសណ្តាន់ ខេត្តកំពង់ធំ ត្រូវប្រើប្រាស់ដូចខាងក្រោម៖

- ដាក់នៅកន្លែងធ្វើការងារនៅរដ្ឋបាលស្រុកសណ្តាន់
- ប្រើប្រាស់នៅលើលិខិត ស្រោមសំបុត្រ និងឯកសារផ្លូវការពាក់ព័ន្ធរបស់រដ្ឋបាលស្រុកសណ្តាន់
- ប្រើប្រាស់ក្នុងពិធីនានា និងប្រើប្រាស់ក្នុងកិច្ចការជាផ្លូវការផ្សេងៗ តាមការចាំបាច់។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស ប្រធានអង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ក្រុមប្រឹក្សានិងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ក្រុមប្រឹក្សានិងអភិបាលនៃគណៈអភិបាលស្រុកសណ្តាន់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...សុក្រ...១១កើត...ខែ...ភទ្របទ...ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...១៣...ខែ...កញ្ញា...ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- រដ្ឋបាលខេត្តកំពង់ធំ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ៥៤៧៩.ប្រក ចុះថ្ងៃ.សុក្រ...១១កើត.ខែ.ភទ្របទ....ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹង ថ្ងៃទី.១៣..ខែ.កញ្ញា...ឆ្នាំ២០២៤ ស្តីពីការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលស្រុកសណ្ដាន់ ខេត្តកំពង់ធំ។

**និមិត្តសញ្ញារដ្ឋបាលស្រុកសណ្ដាន់**

រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងមហាផ្ទៃ

លេខ: ៥៤៣៤ ប្រក

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាស
# ស្តីពី
# ការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញា
# រដ្ឋបាលស្រុកសន្ទុក ខេត្តកំពង់ធំ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- យោងតាមសំណើរបស់រដ្ឋបាលខេត្តកំពង់ធំ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតនិមិត្តសញ្ញារដ្ឋបាលស្រុកសន្ទុក ខេត្តកំពង់ធំ មានរូបរាង រូបភាព និងលក្ខណៈសម្គាល់ដូចខាងក្រោម៖

- និមិត្តសញ្ញាមានរាងរង្វង់មូលព័ទ្ធដោយខ្សែវណ្ឌពីរជាន់ពណ៌មាស បង្ហាញអំពីការគ្រប់គ្រងដែនដីរបស់រដ្ឋបាលស្រុក

- ភ្នំសន្ទុកគ្របដណ្តប់ដោយព្រៃ និងដើមឈើខ្ពស់ៗមានពណ៌បៃតង ជាតំណាងនៃភ្នំពីធម្មជាតិដែលកើតឡើងតាំងពីយូរលង់មកហើយ។ ភ្នំសន្ទុកមានវត្តព្រះពុទ្ធសាសនាបែបបុរាណ រូបសំណាកស្នាមព្រះបាទជាន់ទុក និងកន្លែងគោរពបូជាផ្សេងទៀត សម្រាប់មហាជនគោរពបូជាព្រះពុទ្ធសាសនា និងបន់ស្រន់ក្នុងជំនឿផ្សេងៗ ព្រមទាំងរមណីយដ្ឋានទេសចរណ៍បែបធម្មជាតិសម្រាប់បម្រើភ្ញៀវទេសចរនៅក្នុងស្រុកនិងក្រៅស្រុក
- កំពូលចំនួនបីពណ៌មាស បង្ហាញអំពីត្រៃកូដធម៌ គឺ សច្ចៈ ខន្តី កតញ្ញូ
- ជណ្តើរកសាងពីថ្មជាច្រើនរយកាំដែលក្បាលជណ្តើរអមដោយក្បាច់រូបនាគពណ៌ប្រផេះ បង្ហាញអំពីជណ្តើរឡើងភ្នំសន្ទុកសម្រាប់បម្រើភ្ញៀវទេសចរធ្វើរជើង
- អក្សរឈ្មោះ «រដ្ឋបាលស្រុកសន្ទុក» មានពណ៌ស រំលេចក្នុងផ្ទៃពណ៌ក្រហមអមដោយខ្សែបូពណ៌ខៀវ
- ផ្ទៃពណ៌ស បង្ហាញអំពីភាពជឿជាក់ ភាពស្មោះត្រង់ និងភាពត្រជាក់ត្រជុំ។

**ប្រការ២ .-**

ត្រូវបានដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលស្រុកសន្ទុក ខេត្តកំពង់ធំ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

និមិត្តសញ្ញារដ្ឋបាលស្រុកសន្ទុក ខេត្តកំពង់ធំ ត្រូវប្រើប្រាស់ដូចខាងក្រោម៖

- ដាក់នៅកន្លែងធ្វើការងារនៅរដ្ឋបាលស្រុកសន្ទុក
- ប្រើប្រាស់នៅលើលិខិត ស្រោមសំបុត្រ និងឯកសារផ្លូវការពាក់ព័ន្ធរបស់រដ្ឋបាលស្រុកសន្ទុក
- ប្រើប្រាស់ក្នុងពិធីនានា និងប្រើប្រាស់ក្នុងកិច្ចការជាផ្លូវការផ្សេងៗ តាមការចាំបាច់។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានកស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស ប្រធានអង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ប្រធានក្រុមប្រឹក្សានិងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ប្រធានក្រុមប្រឹក្សានិងអភិបាលនៃគណៈអភិបាលស្រុកសន្ទុក ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ.សុក្រ...១១កើត... ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១៣..ខែ.កញ្ញា.....ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- រដ្ឋបាលខេត្តកំពង់ធំ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ៥៤៨៣៤...ប្រក ចុះថ្ងៃសុក្រ....១១កើត.ខែភទ្របទ.ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី.១៣...ខែ.កញ្ញា....ឆ្នាំ២០២៤ ស្តីពីការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលស្រុកសន្ទុក ខេត្តកំពង់ធំ។

**និមិត្តសញ្ញារដ្ឋបាលស្រុកសន្ទុក ១៥**

រដ្ឋបាលស្រុកសន្ទុក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៥៤៧៥ ប្រកា

# ប្រកាស
# ស្ដីពី
# ការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញា
# រដ្ឋបាលស្រុកស្ទោង ខេត្តកំពង់ធំ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនង ការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- យោងតាមសំណើរបស់រដ្ឋបាលខេត្តកំពង់ធំ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតនិមិត្តសញ្ញារដ្ឋបាលស្រុកស្ទោង ខេត្តកំពង់ធំ មានរូបរាង រូបភាព និងលក្ខណៈសម្គាល់ដូចខាងក្រោម៖

- និមិត្តសញ្ញាមានរាងមូលព័ទ្ធដោយខ្សែវណ្ឌមួយជាន់ពណ៌ខៀវ បង្ហាញអំពីការគ្រប់គ្រងដែនដីរបស់រដ្ឋបាលស្រុក
- ធ្នូពណ៌មាសដាក់ព្បួរជាប់នឹងសសរប្រាំបីជ្រុង ដែលមានទម្រខឿនបីជាន់ពណ៌មាស ជាតំណាងនៃអាវុធមួយប្រភេទសម្រាប់បាញ់ព្រួញរបស់ស្ដេចព្រះនាមថាព្រះបាទសិន្ធោ ដែលបានគង់នៅស្រុកស្ទោង នៅក្នុងរឿងព្រេងខ្មែរបក្សីចាំក្រុង។ ធ្នូនេះរចនាក្បាច់ចុងសងខាងជាសត្វនាគ ជាអាវុធទិព្វមានមហិទ្ធិឫទ្ធិពូកែអស្ចារ្យណាស់ បាញ់ម្ដងបានប្រាំព្រួញសូរសំឡេងប្រៀបដូចរន្ទះបាញ់ ហើយធ្នូនេះមិនអាចដាក់ផ្ទាល់នឹងដីនិងលើគ្រែបានឡើយ ទើបព្រះបាទសិន្ធោសង់ប្រាសាទធ្វើពីឥដ្ឋសម្រាប់ទុកព្បួរធ្នូនិងសសរប្រៀបដូចនឹងទោង ហើយអ្នកភូមិនិយមហៅថាសរទោង ឬពាក្យស្ទោងរហូតដល់សព្វថ្ងៃនេះ
- សសរប្រាំបីជ្រុងមានកំពូលរចនាជាកំពូលប្រាសាទបក្សីចាំក្រុងពណ៌មាស សសរនេះទ្រដោយខឿនបីថ្នាក់ ដែលថ្នាក់ផ្ទាល់ដីឬខាងក្រោមមានសត្វតោពណ៌មាសចំនួន៤ក្បាល ថ្នាក់កណ្ដាលបង្គោលសីមាពណ៌មាស និងថ្នាក់ខាងលើមានប្រាំជ្រុង បង្ហាញអំពីភាពរឹងមាំក្នុងការតម្កល់រក្សាទុកធ្នូ
- អក្សរឈ្មោះ «រដ្ឋបាលស្រុកស្ទោង» មានពណ៌ស រំលេចក្នុងខ្សែបូពណ៌ក្រហម អមដោយខ្សែពណ៌ខៀវ
- ផ្ទៃពណ៌ស បង្ហាញអំពីភាពជឿជាក់ ភាពស្មោះត្រង់ និងភាពត្រជាក់ត្រជុំ។

**ប្រការ២ .-**

ត្រូវបានដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលស្រុកស្ទោង ខេត្តកំពង់ធំ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

និមិត្តសញ្ញារដ្ឋបាលស្រុកស្ទោង ខេត្តកំពង់ធំ ត្រូវប្រើប្រាស់ដូចខាងក្រោម៖

- ដាក់នៅកន្លែងធ្វើការងារនៅរដ្ឋបាលស្រុកស្ទោង
- ប្រើប្រាស់នៅលើលិខិត ស្រោមសំបុត្រ និងឯកសារផ្លូវការពាក់ព័ន្ធរបស់រដ្ឋបាលស្រុកស្ទោង
- ប្រើប្រាស់ក្នុងពិធីនានា និងប្រើប្រាស់ក្នុងកិច្ចការជាផ្លូវការផ្សេងៗ តាមការចាំបាច់។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស ប្រធានអង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ប្រធានក្រុមប្រឹក្សានិងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ប្រធានក្រុមប្រឹក្សានិងអភិបាលនៃគណៈអភិបាលស្រុកស្ទោង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ......១១កើត..... ខែ......ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១៣..ខែ.......ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- រដ្ឋបាលខេត្តកំពង់ធំ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ៥៤៣៥ប្រក ចុះថ្ងៃ.សុក្រ...១១កើត..ខែភទ្របទ.....ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹង ថ្ងៃទី១៣.ខែកញ្ញា.ឆ្នាំ២០២៤ ស្តីពីការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលស្រុកស្ទោង ខេត្តកំពង់ធំ។

**និមិត្តសញ្ញារដ្ឋបាលស្រុកស្ទោង១/៥**

ទ.៥